## មជ្ឈមណ្ឌលឯកសារកម្ពុជា

## កម្មវិធីវិទ្យុសហគមន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា
## សម្លេងយុត្តិធម៌៖   អំពើប្រល័យពូជសាសន៍ និងការអត់ឃ្លាននៅក្នុងរបបខ្មែរក្រហម

# វគ្គទី១០
# ប្រធានបទ៖ ការអត់ឃ្លាន ការចងចាំ និងយុត្តិធម៌

*ដោយ ៖ រ៉េនឌល ឌីហ្វាល់កូ*

*ជាមួយនឹង ម៉ែន ពិចិត្រ និង លន់ ដាលីន*

*អានដោយ ៖ ឌី ខាំបូលី និង កន ពេញសំណាង*

*សហការជាមួយបន្ទប់ថតសម្លេងរបស់ស្ថានីយវិទ្យុផ្សាយសម្លេងសហរដ្ឋអាមេរិក-រាជធានីភ្នំពេញ*

*ខែធ្នូ ឆ្នាំ២០១៣*

*ជម្រាបសួរប្រិយមិត្តអ្នកស្តាប់កម្មវិធីវិទ្យុសហគមន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាទីមេត្រី! នេះគឺជាការផ្សាយវគ្គទី១០ និងជាវគ្គបញ្ចប់ ក្នុងចំណោមការផ្សាយទាំង១០វគ្គ នៃកម្មវិធីវិទ្យុរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ដែលពិនិត្យទៅលើទិដ្ឋភាពប្រវត្តិសាស្ត្រ និងច្បាប់ផ្សេងៗទាក់ទងនឹងការអត់ឃ្លានដែលបានកើតមានឡើងនៅក្នុងប្រទេសកម្ពុជាក្នុងរបបខ្មែរក្រហមចន្លោះពី ឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ ។ គោលបំណងសំខាន់របស់កម្មវិធីវិទ្យុនេះ គឺដើម្បីផ្សព្វផ្សាយឲ្យប្រជាជនកម្ពុជាទាំងអស់បានដឹងច្បាស់អំពីសាច់រឿងផ្ទាល់ខ្លួនរបស់ជនរងគ្រោះដែលពាក់ព័ន្ធនឹងការអត់ឃ្លាន និងជំរុញឲ្យមានការចូលរួមនៅក្នុងដំណើរការស្វែងរកយុត្តិធម៌ ។*

*ប្រសិនបើប្រិយមិត្តអ្នកស្តាប់ចង់ចូលរួមផ្តល់ជាមតិយោបល់ សួរសំណួរ ឬមានចម្ងល់ផ្សេងៗនៅក្នុងកម្មវិធីសូមសរសេរជាលិខិតផ្ញើមកកាន់ លោក ម៉ែន ពិចិត្រ អ្នករៀបចំកម្មវិធីរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ដែលមានអាសយដ្ឋានផ្ទះលេខ ៦៦ មហាវិថីព្រះសីហនុ រាជធានីភ្នំពេញ ឬប្រអប់ សំបុត្រលេខ ១១១០ រាជធានីភ្នំពេញ ឬទំនាក់ទំនងតាមរយៈទូរស័ព្ទលេខ ០២៣-២១១-៨៧៥ ឬទូរសារលេខ ០២៣-២១០-៣៥៨ ។ កម្មវិធីរបស់យើងខ្ញុំចាក់ផ្សាយរៀងរាល់ថ្ងៃអាទិត្យតាមរយៈវិទ្យុដូចខាងក្រោម ។ វគ្គនីមួយៗនឹងត្រូវចាក់ផ្សាយចំនួនបួនដងក្នុងមួយខែ ។ រៀងរាល់ដើមខែ យើងខ្ញុំនឹងលើកយកវគ្គថ្មីមកចាក់ផ្សាយជូនប្រិយមិត្តអ្នកស្តាប់ ។ ចំពោះប្រិយមិត្តអ្នកស្តាប់ដែលរស់នៅរាជធានីភ្នំពេញ និង ខេត្តដែលនៅជាប់នឹងរាជធានីភ្នំពេញអាចស្តាប់កម្មវិធីវិទ្យុសហគមន៍របស់យើងខ្ញុំ តាមរយៈវិទ្យុជាតិកម្ពុជា FM105.75 MHz រាជធានីភ្នំពេញ វេលាម៉ោង ៩ព្រឹក*

និង ម៉ោង៧និង៣០នាទីល្ងាច ។ នៅខេត្តកំពត តាមរយៈ វិទ្យុខេត្តកំពត FM93.25 វេលា ម៉ោង ៧ព្រឹក និង ម៉ោង៧ល្ងាច ។ នៅខេត្តព្រះវិហារ តាមរយៈ វិទ្យុខេត្តព្រះវិហារ FM99 វេលា ម៉ោង ៧និង៣០នាទីព្រឹក និងម៉ោង៨រសៀល ។ នៅខេត្តបាត់ដំបង តាមរយៈវិទ្យុខេត្ត បាត់ដំបង FM 103.25 វេលាម៉ោង ៨ព្រឹក និងម៉ោង៨រសៀល ។ យើងខ្ញុំ នឹងធ្វើការចាក់ផ្សាយឡើងវិញ ពីវគ្គទី១ នៅដើមខែមករាឆ្នាំ២០១៨ ខាងមុខនេះ ។

ការផ្សាយនៅក្នុងវគ្គនេះ យើងខ្ញុំនឹងធ្វើការសង្ខេបឡើងវិញនូវបញ្ហាមួយចំនួនដែលបានលើកយកមកពិភាក្សាកាលពីវគ្គទី១ដល់វគ្គទី៩ ដែលកម្មវិធីវិទ្យុយើងខ្ញុំបានផ្សាយកន្លងមក ។ លើសពីនេះទៅទៀត យើងខ្ញុំនឹងផ្តល់ជាសេចក្តីសន្និដ្ឋានខ្លះៗទាក់ទងទៅនឹងបញ្ហាយុត្តិធម៌ ការអត់ឃ្លាននៅក្នុងរបបខ្មែរក្រហម និងបង្ហាញថាតើ កេរ្តិ៍ដំណែលនៃសោកនាដកម្មដែលបានបន្សល់ពីរបបខ្មែរក្រហម បានបន្តប៉ះពាល់ដល់សង្គម ក៏ដូចជានយោបាយរបស់ប្រទេសកម្ពុជាយ៉ាងដូចម្តេចខ្លះ ។

## ការអត់ឃ្លាន និងយុត្តិធម៌នៅក្នុងប្រទេសកម្ពុជាៈ តើយើងបានរៀនសូត្រអ្វីខ្លះពីបញ្ហានេះ?

ខណៈដែលកម្មវិធីវិទ្យុសហគមន៍របស់យើងខ្ញុំឈានមកដល់វគ្គទី១០ ដែលជាវគ្គចុងក្រោយ សំណុំរឿង០០២ផ្នែកទីមួយ នៅឯតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម ក៏ឈានដល់ដំណាក់កាលចុងបញ្ចប់ដែរ ។ នាពេលថ្មីៗកន្លងទៅនេះ អង្គជំនុំជម្រះសាលាដំបូងបានបើកសវនាការ ស្តាប់សេចក្តីសន្និដ្ឋានបិទសំណុំរឿង០០២ផ្នែកទីមួយ ដែលពាក់ព័ន្ធនឹងជនជាប់ចោទ នួន ជា និងខៀវ សំផន ។ ខណៈដែលសំណុំរឿង០០២ផ្នែកទីមួយ ផ្តោតសំខាន់ទៅលើឧក្រិដ្ឋកម្មជាក់លាក់មួយចំនួន ដែលពាក់ព័ន្ធទៅនឹងការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ និងព្រឹត្តិការណ៍ផ្សេងៗទៀត ដែលបានកើតឡើងមុនពេលខ្មែរក្រហមឡើងកាន់អំណាច ។ បញ្ហានៃការអត់ឃ្លាន និងការបង្អត់អាហារ ដូចជា ការកំណត់របបអាហារ ការនាំស្រូវចេញទៅក្រៅប្រទេស និងគោលនយោបាយទូទៅចំពោះការធ្វើកសិកម្ម និងការចែកចាយអាហារនៅក្នុងរបបខ្មែរក្រហម ក៏បានលើកយកមកពិភាក្សាក្នុងអំឡុងពេល នៃសវនាការនៅក្នុងសំណុំរឿង០០២ផ្នែកទីមួយនេះដែរ ។ ប៉ុន្តែ ដោយផ្អែកទៅលើវិសាលភាពនៃសំណុំរឿង០០២ផ្នែកទីមួយនេះ អង្គជំនុំជម្រះសាលាដំបូង នឹងមិនលើកយកបញ្ហានៃការអត់ឃ្លាន និងការបង្អត់អាហារមកធ្វើការពិនិត្យពិច័យនៅក្នុងសាលក្រមនោះឡើយ ។ សាលក្រមនៃសំណុំរឿង០០២ផ្នែកទីមួយ ត្រូវបានរំពឹងថានឹងប្រកាសនៅពាក់កណ្តាលឆ្នាំ២០១៤ ខាងមុខនេះ ។ លក្ខខណ្ឌរស់នៅទូទៅរបស់ប្រជាជនកម្ពុជាក្រោមរបបខ្មែរក្រហម រួមមាន ការបង្អត់អាហារ និងការធ្វើការហួសកម្លាំង អាចនឹងត្រូវលើក

យកមកពិនិត្យពិច័យនៅក្នុងសំណុំរឿងផ្នែកផ្សេងទៀតនៃសំណុំរឿង០០២ នៅចំពោះមុខតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម ។ លោក វីលៀម ស្មីត (William Smith) ដែលជាសហព្រះរាជអាជ្ញាអន្តរជាតិនៅឯតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម បានកត់សំគាល់ថា សំណុំរឿង០០២ផ្នែកទីមួយ ដែលទើបតែបញ្ចប់ «គឺជាចំណុចចាប់ផ្តើមនៃសំណុំរឿង០០២ ។ សំណុំរឿងផ្នែកផ្សេងៗទៀតនៃសំណុំរឿង០០២ គួរតែចាប់ផ្តើមឲ្យបានលឿន ។ វាមានសារៈសំខាន់ណាស់ ដែលបទចោទប្រកាន់ផ្សេងទៀតត្រូវតែលើកយកមកកាត់សេចក្តី ដោយសារតែ រហូតមកដល់បច្ចុប្បន្ននេះ មានតែមួយភាគបីប៉ុណ្ណោះនៃរឿងរ៉ាវនៃរបបខ្មែរក្រហម ត្រូវបានលើកយកមកពិភាក្សា ។» ទោះបីជាតុលាការបានបញ្ចប់សំណុំរឿង០០២ផ្នែកទីមួយក៏ដោយ ក៏យើងនៅតែស្ថិតក្នុងភាពស្រពិចស្រពិលនៅឡើយ ថាតើតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម និងជនជាប់ចោទទាំងពីររូប អាចមានលទ្ធភាពបន្តចូលរួមនៅក្នុងសវនាការនៃសំណុំរឿងផ្សេងទៀតរបស់តុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមដែរឬទេ ។

បទពិសោធន៍ដែលទទួលបានពីការបើកសវនាការពិនិត្យភស្តុតាង បានជួយឲ្យសហគមន៍ជាតិ និងអន្តរជាតិ យល់ដឹងកាន់តែច្បាស់អំពីលក្ខខណ្ឌរស់នៅប្រចាំថ្ងៃរបស់ប្រជាជនកម្ពុជា នៅក្នុងរបបខ្មែរក្រហម និងបានដឹង ថាតើមេដឹកនាំខ្មែរក្រហម ដែលបានអះអាងថា ខ្លួនបានរំដោះប្រទេសកម្ពុជាឲ្យចេញពីអំពើពុករលួយ និងការជ្រៀតជ្រែករបស់បរទេស បានធ្វើឲ្យប្រជាជនរបស់ខ្លួនធ្លាក់ចូលទៅក្នុងអន្ទង់នៃសេចក្តីឈឺចាប់ និងការស្លាប់រង្គាលដោយរបៀបណា ។

ផ្អែកទៅលើភស្តុតាង ដែលបានលើកឡើងនៅចំពោះមុខតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម និងឯកសារស្រាវជ្រាវផ្សេងៗ ដែលពាក់ព័ន្ធទៅនឹងរបបខ្មែរក្រហម ក៏ដូចជា អត្ថបទសម្ភាសន៍ផ្សេងៗ បានបង្ហាញថា មេដឹកនាំខ្មែរក្រហម មានបំណងធ្វើការកែប្រែប្រទេសកម្ពុជា ឲ្យទៅជាប្រទេសសង្គមនិយមមួយ ក្នុងល្បឿនដែលពិបាកនឹងសម្រេចបាន ។ នៅក្នុងដំណើរការប្រែក្លាយប្រទេសកម្ពុជា ឲ្យទៅជាប្រទេសសង្គមនិយម មេដឹកនាំខ្មែរក្រហម បានរិបអូសទ្រព្យសម្បត្តិ និងបំបិទកម្មសិទ្ធិឯកជន ដូចជា ការធ្វើស្រែចម្ការ ការចំអិនអាហារ ការបរិភោគអាហារជាលក្ខណៈគ្រួសារ និងសកម្មភាពផ្សេងៗដែលមានលក្ខណៈឯកជន ។ មិនតែប៉ុណ្ណោះ មេដឹកនាំខ្មែរក្រហម មានបំណងធ្វើឲ្យបដិវត្តន៍របស់ខ្លួនមានភាពស្អាតស្អំ និងមានភាពជឿនលឿន ជាងប្រទេសកុម្មុយនីស្តដទៃទៀត ដូចជា ប្រទេសចិន និងប្រទេសវៀតណាម ជាដើម ។ ជាងនេះទៅទៀត មេដឹកនាំខ្មែរក្រហម បានសម្រេចចិត្តបិទប្រកព្រំដែន និងអនុវត្តគោលនយោបាយពឹងពាក់លើខ្លួនឯង ដោយសារតែ មេដឹកនាំខ្មែរក្រហម យល់ថា មានការជ្រៀតជ្រែកពីសំណាក់ចលនាបដិវត្តន៍សង្គមនិយមនៅអាស៊ីអាគ្នេយ៍ ដោយក្នុងនោះ រួមមាន បក្សកុម្មុយនីស្តឥណ្ឌូចិនដឹកនាំដោយវៀតណាម និងការជ្រៀតជ្រែកពីប្រទេសចក្រពត្តិនិយម ។

លទ្ធផលនៃការប្រែប្រទេសឲ្យទៅជាប្រទេសសង្គមនិយមស្អាតស្អំ និងឯករាជ្យក្នុងល្បឿនលឿនពេក បានបំផ្លាញសង្គមកម្ពុជាស្ទើរតែទាំងស្រុង ហើយបានបណ្តាលឲ្យប្រជាជនជាច្រើននាក់ស្លាប់ដោយសារការសម្លាប់ និងលក្ខខណ្ឌការរស់នៅយ៉ាងអាក្រក់ ដូចជា ការអត់ឃ្លាន និងការបង្អត់អាហារ ។ តុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម ទំនងជាមិនធ្វើការកាត់ទោសមេដឹកនាំខ្មែរក្រហមទៅលើឧក្រិដ្ឋកម្ម ដែលពាក់ព័ន្ធទៅនឹងការអត់ឃ្លាន ដែលបានកើតមានឡើងចំពោះប្រជាជនកម្ពុជានៅក្នុងរបបខ្មែរក្រហម ចន្លោះពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ នោះទេ ។ ប៉ុន្តែ នេះមិនបានបញ្ជាក់ថា យើងគួរតែបំភ្លេចចោលនូវសោកនាដកម្ម ដែលបានកើតឡើងដោយសារការអត់ឃ្លាន ឬចាត់ទុកថារឿងរ៉ាវទាំងនេះ គឺជាគ្រោះមហន្តរាយធម្មជាតិ ដូចជា គ្រោះរាំងស្ងួត ឬទឹកជំនន់ តែមិនមែនជាឧក្រិដ្ឋកម្មនោះឡើយ ។ យើងខ្ញុំធ្លាប់បានលើកឡើងក្នុងវគ្គមុនហើយថា ការអត់ឃ្លានដែលបានកើតឡើងនៅក្នុងរបបខ្មែរក្រហម គួរតែត្រូវបានចងចាំទុក និងលើកយកមកពិភាក្សាតាមផ្លូវច្បាប់ ជាពិសេសឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ។

## កេរ្តិ៍ដំណែលពីការអត់ឃ្លាននៅក្នុងរបបខ្មែរក្រហម

បើទោះបីជា របបខ្មែរក្រហមបានកន្លងផុតទៅជាងបីទសវត្សរ៍ហើយក៏ដោយ ក៏ស្លាកស្នាមដែលសល់ពីការបំផ្លិចបំផ្លាញរបស់ខ្មែរក្រហម ដោយរួមបញ្ចូលទាំងលក្ខខណ្ឌនៃការអត់ឃ្លាន នៅតែបន្តប៉ះពាល់ទៅលើសង្គម និងនយោបាយរបស់កម្ពុជានាពេលបច្ចុប្បន្ន ។ អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម នៅតែទទួលរងការប៉ះពាល់ទាំងផ្លូវកាយ និងផ្លូវចិត្ត ដោយសារតែលក្ខខណ្ឌនៃការអត់ឃ្លានដ៏អាក្រក់ ដែលបានកើតឡើង ។ អត្រាកំណើតទារក ក៏មានការថយចុះ ដោយសារតែការអត់ឃ្លានដែលទទួលរងនៅក្នុងរបបខ្មែរក្រហម ។ នេះមានន័យថា គ្រួសារជាច្រើនមិនត្រឹមតែបាត់បង់សមាជិកគ្រួសារប៉ុណ្ណោះទេ ថែមទាំងមិនអាចផ្តល់កំណើតដល់សមាជិកថ្មី ក្នុងចន្លោះពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ ។ ប្រសិនបើ មានការផ្តល់កំណើតនៅក្នុងរបបនោះ ម៉្លោះបុគ្គលទាំងនោះ ក្លាយជាមនុស្សធំពេញវ័យមិនបាន ។ ជាងនេះទៅទៀត សមាជិកថ្មី ដែលបានចាប់កំណើតនៅក្នុងរបបខ្មែរក្រហម ដែលម្តាយរបស់ខ្លួនជួបប្រទះការអត់ឃ្លាន អាចប្រឈមមុខនឹងបញ្ហាសុខភាព នេះបើយោងតាមការសិក្សាផ្នែកវេជ្ជសាស្ត្រ ។

ទន្ទឹមនឹងការប៉ះពាល់ដោយផ្ទាល់ទៅលើបុគ្គល និងក្រុមគ្រួសារ ដែលជាអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម បទពិសោធន៍នៃការឆ្លងកាត់ការអត់ឃ្លាន ក៏បានប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់សង្គម និង

នយោបាយរបស់កម្ពុជាដែរ ។ បន្ទាប់ពីរបបខ្មែរក្រហមបានដួលរលំ សង្គមជាតិទាំងមូលបានបន្តប្រឈមមុខនឹងជម្លោះផ្ទៃក្នុងដ៏រ៉ាំរ៉ៃ ។ អស់រយៈពេលជាច្រើនទសវត្សរ៍ ការភ័យខ្លាចចំពោះការកើតឡើងនូវជម្លោះ និងការចងចាំពីការអត់ឃ្លាន បានធ្វើឲ្យប្រជាជនកម្ពុជាភាគច្រើន យកចិត្តទុកដាក់ទៅលើតែការរស់នៅរបស់ខ្លួន ។ មិនតែប៉ុណ្ណោះ ប្រជាជនកម្ពុជា ចាប់ផ្តើមមានភាពសង្ស័យទៅលើរបត់នយោបាយ ការធ្វើបាតុកម្ម និងចលនាដទៃទៀត ដែលអាចបង្កជាភាពមិនប្រក្រតីនៅក្នុងសង្គម ។ នៅពេលដែលអ្នកដែលរស់រានមានជីវិតពីរបបខ្មែរក្រហម ពិចារណាពីគុណសម្បត្តិ និងគុណវិបត្តិនៃការធ្វើបាតុកម្ម ឬការទាមទារផ្សេងៗ បុគ្គលទាំងនោះរមែងតែសម្រេចចិត្ត ដោយផ្អែកទៅលើអ្វីដែលខ្លួនបានចងចាំទាក់ទងយ៉ាងច្បាស់ទៅនឹងការអត់ឃ្លាននៅក្នុងរបបខ្មែរក្រហម ដែលជាលទ្ធផលនៃការធ្វើបដិវត្តន៍របស់ខ្មែរក្រហមចំពោះអំពើពុករលួយ និងភាពអយុត្តិធម៌ ដែលធ្លាប់បានកើតឡើង ។ ជាលទ្ធផល មនុស្សភាគច្រើន ផ្តោតការយកចិត្តទុកដាក់ស្ទើរតែទាំងស្រុងទៅលើ ការសម្រេចឲ្យបាននូវស្ថេរភាព និងសន្តិភាព ជាជាងការអភិវឌ្ឍន៍សង្គមប្រជាធិបតេយ្យ និងការការពារសិទ្ធិមនុស្ស ។

ការឈឺចាប់ និងរបួសដែលសេសសល់ពីរបបខ្មែរក្រហម ចាប់ផ្តើមធូរស្រាលមកវិញ ដោយសារតែ ពេលវេលា និងកិច្ចខិតខំប្រឹងប្រែងក្នុងការស្វែងរកយុត្តិធម៌ ការផ្សះផ្សាជាតិ និងការដាក់ឲ្យទទួលខុសត្រូវចំពោះបទឧក្រិដ្ឋកម្ម ដែលបានកើតឡើងនៅក្នុងរបបខ្មែរក្រហម តាមរយៈការបង្កើតតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម និងសកម្មភាពដទៃទៀត ។ លទ្ធិប្រជាធិបតេយ្យនៅក្នុងប្រទេសកម្ពុជា បានឈានទៅរកភាពប្រសើរជាមុន នៅពេលដែលមានការពិភាក្សា និងការផ្លាស់ប្តូរយោបល់គ្នា ។ និស្សិតកម្ពុជា ដែលសិក្សាផ្នែកច្បាប់ជាច្រើន ចាប់ផ្តើមចាប់អារម្មណ៍ទៅលើបញ្ហាសិទ្ធិមនុស្ស ច្បាប់ និងភាពឯករាជ្យរបស់ស្ថាប័នច្បាប់ ។ ប្រជាជនកម្ពុជា ចាប់ផ្តើមហ៊ានបញ្ចេញមតិយោបល់ នៅដែលយល់ឃើញថា សិទ្ធិរបស់ខ្លួនត្រូវបានរំលោភបំពាន ឬក៏មិនទាន់ទទួលបានសិទ្ធិប្រជាធិបតេយ្យពេញលេញ តាមរយៈការធ្វើបាតុកម្មអហិង្សា និងការពិភាក្សាជាសាធារណៈ ។ នេះសបញ្ជាក់ឲ្យឃើញថា ប្រជាជនកម្ពុជា ដែលកាលពីប៉ុន្មានទសវត្សរ៍មុន ដែលជាមនុស្សគិតតែពីជីវភាពប្រចាំថ្ងៃ ដោយសារតែខ្លួនធ្លាប់ឆ្លងកាត់ការអត់ឃ្លាន អំពើហិង្សា និងការបំបិទសិទ្ធិសេរីភាព ចាប់ផ្តើមហ៊ានសង្ឃឹមច្រើនជាងមុន ពោគគឺ លើសពីការរស់នៅប្រចាំថ្ងៃ និងសង្ឃឹមថា ប្រទេសរបស់ខ្លួននឹងចាកផុតពីសង្គ្រាមរ៉ាំរ៉ៃ និងអំពើហិង្សា ។ ទាមរយៈការខិតខំប្រឹងប្រែងពង្រឹងអភិបាលកិច្ចល្អ និងការអភិវឌ្ឍន៍ប្រកមដោយសមភាព សបញ្ជាក់ពីភាពវិជ្ជមាន ដែលតាមរយៈកិច្ចខិតខំប្រឹងប្រែងនេះ ប្រជាជនកម្ពុជាទាំងអស់នឹងអាចព្យាបាលរបួស ដែលបានបន្សល់ទុកពីរបបខ្មែរក្រហម ។

(ជាបន្តទៅនេះ យើងខ្ញុំសូមលើកសំណួររបស់ប្រិយមិត្តអ្នកស្តាប់ដែលបានផ្ញើមកកាន់វិទ្យុសហគមន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ។)

**សំណួររបស់ប្រិយមិត្តអ្នកស្តាប់**

**ឆ្លើយដោយ លោក *វ៉េនឌល ឌឺហ្វាល់គូ***

១. ហេតុអ្វីបានជាខ្មែរក្រហមបង្អត់បាយប្រជាជនខ្លួនឯង នៅពេលដែលផលដំណាំមានច្រើន? តើផលដំណាំទាំងនោះត្រូវបានខ្មែរក្រហមដឹកជញ្ជូនទៅណា?

- <u>ចម្លើយ</u>៖ ទីមួយ ខ្មែរក្រហមមានគម្រោងផលិតស្រូវឲ្យបានច្រើន ពោលគឺ ៣តោនក្នុង ១ហិចតា ។ ប៉ុន្តែ ទិន្នផលនេះមិនធ្លាប់ទទួលបានជោគជ័យនោះទេ នៅពេលដែលខ្មែរក្រហមកាន់អំណាច ។ ទីពីរ ផែនការសេដ្ឋកិច្ចរបស់ខ្មែរក្រហម គឺប្រែក្លាយប្រទេសកម្ពុជាឲ្យទៅជាប្រទេសឧស្សាហកម្មជឿនលឿន តាមរយៈការលក់ស្រូវទៅកាន់ទីផ្សារអន្តរជាតិ ដើម្បីរកប្រាក់ចំណូលបន្ថែមសម្រាប់អនុវត្តផែនការរបស់ខ្លួន ។ កត្តាទាំងអស់នេះ បានបង្កជាសម្ពាធយ៉ាងខ្លាំងដល់កម្មាភិបាលថ្នាក់ក្រោមតាមតំបន់ ដោយធ្វើយ៉ាងណាផ្តល់នូវទិន្នផលស្រូវឲ្យបានគ្រប់តាមផែនការកំណត់ របស់ថ្នាក់ដឹកនាំមជ្ឈិម ដើម្បីផ្គត់ផ្គង់ដល់យោធាខ្មែរក្រហម និងលក់ទៅប្រទេសដទៃ សម្រាប់ដោះដូរជាប្រាក់កាស និងទំនិញដែលខ្មែរក្រហមមិនអាចផលិតបាន ។

២. ហេតុអ្វីបានជាខ្មែរក្រហមឲ្យប្រជាជនធ្វើការធ្ងន់?

- <u>ចម្លើយ</u>៖ ខ្មែរក្រហមបានថ្លែងថា គោលនយោបាយរបស់ខ្លួនគឺ រស់នៅឯករាជ្យម្ចាស់ការ នេះមានន័យថា មិនមានជំនួយបរទេសនោះទេ ។ ខ្មែរក្រហមក៏ មានគម្រោងធ្វើឲ្យប្រទេសកម្ពុជាឈានឆ្ពោះទៅមុខ "មហាលោតផ្លោះ" ដើម្បីក្លាយជាប្រទេសសង្គមនិយមមួយដ៏រីកចម្រើន និង ធ្វើឲ្យប្រទេសកម្ពុជាមានការរីកលូតលាស់ជាងប្រទេសសង្គមនិយមដទៃទៀត ដូចជា ប្រទេសចិន និងប្រទេសវៀតណាម ជាដើម ។ ដោយសារតែ ខ្មែរក្រហមពឹងផ្អែកទាំងស្រុងទៅលើកម្លាំងពលកម្មប្រជាជន ដើម្បីសម្រេចឲ្យផែនការរបស់ខ្លួន ជាលទ្ធផល ប្រជាជនកម្ពុជាត្រូវបានខ្មែរក្រហមបង្ខំឲ្យធ្វើការធ្ងន់ធ្ងរ និងច្រើនម៉ោង ។

៣. ហេតុអ្វីបានជាខ្មែរក្រហមសម្លាប់ប្រជាជនខ្លួនឯង?

- <u>ចម្លើយ</u>៖ វាមានកត្តាជាច្រើនដែលបានបណ្តាលឲ្យប្រជាជនកម្ពុជាស្លាប់ក្នុងទ្រង់ទ្រាយធំ ។ កត្តាទាំងនោះ រួមមាន ការកាប់សម្លាប់ លក្ខខណ្ឌរស់នៅ និងការបង្អត់អាហារ ។ ខ្មែរក្រហមមានបំណងប្រែក្លាយប្រទេសកម្ពុជាឲ្យទៅជាប្រទេសសង្គមនិយមមួយដ៏បរិសុទ្ធ ។ ខ្មែរក្រហមយល់

ឃើញថា ខ្លួនមានសត្រូវជាច្រើន ទាំងជនជាតិខ្មែរ និងជនជាតិបរទេស ដែលធ្វើការរារាំងផែនការបដិវត្តន៍របស់ខ្លួន ។ ជាលទ្ធផល ខ្មែរក្រហមមានការភ័យខ្លាច និងព្រួយបារម្ភកាន់តែខ្លាំងឡើងៗចំពោះបញ្ហានេះ ។ មេដឹកនាំខ្មែរក្រហមក៏បានស្តីបន្ទោសទៅលើខ្មាំងបង្កប់ស៊ីរូងផ្ទៃក្នុង ដែលបានធ្វើឲ្យផែនការផលិតស្រូវឲ្យបានបីតោនក្នុងមួយហិចតារបស់ខ្លួនបរាជ័យ ។ ដូច្នេះ នៅតំបន់ណាដែលមិនអាចបំពេញតាមផែនការរបស់ខ្មែរក្រហមបាន ខ្មែរក្រហមចាប់ផ្តើមធ្វើការបោសសំអាតតំបន់នោះដោយអំពើហិង្សា ។ ដោយសារតែ មានការប្រើអំពើហិង្សា និងលក្ខខណ្ឌរស់នៅមិនសមរម្យ កត្តាទាំងអស់នេះបានបង្កឲ្យការសម្លាប់ប្រជាជនក្នុងលក្ខណៈទ្រង់ទ្រាយធំ ។

៤. ហេតុអ្វីបានជាខ្មែរក្រហមបំបែកគ្រួសារមិនឲ្យរស់នៅជុំគ្នា?

- ចម្លើយៈ មេដឹកនាំខ្មែរក្រហមដឹងថា គ្រួសារមានសារៈសំខាន់ និងទំនាក់ទំនងគ្នាយ៉ាងជិតស្និទ្ធនៅក្នុងសង្គមខ្មែរ ។ មេដឹកនាំខ្មែរក្រហមគិតថា ប្រជាជនកម្ពុជាគ្រប់រូបគួរតែស្មោះត្រង់នឹងបដិវត្តន៍របស់ខ្លួនជាងសមាជិកគ្រួសារ ។ មេដឹកនាំខ្មែរក្រហម ក៏ប្រមើលមើលឃើញថា គ្រួសារ គឺជាបញ្ហាប្រឈមមួយ ចំពោះផែនការប្រែក្លាយប្រទេសកម្ពុជាឲ្យទៅជារដ្ឋសង្គមនិយមមួយដ៏ស្អាតស្អំ ។ ដូច្នេះ ដើម្បីសម្រេចផែនការនេះ ខ្មែរក្រហមមិនបានគិតពីទំនាក់ទំនងគ្រួសារនៅក្នុងសង្គមកម្ពុជានោះទេ ។ ហេតុផលមួយផ្សេងទៀតចំពោះការបំបែកបំបាក់គ្រួសារ ដោយសារតែ ខ្មែរក្រហមត្រូវការកម្លាំងពលកម្មដើម្បីបំពេញការងារទៅតាមគោលដៅបដិវត្តន៍ ដូច្នេះ ប្រជា ជនត្រូវបានខ្មែរក្រហមបញ្ជូនទៅកាន់តំបន់ផ្សេងៗពីគ្នា ។

៥. ហេតុអ្វីបានជាមិនមានប្រជាជនណាម្នាក់ធ្វើការប៉ះបោរនឹងខ្មែរក្រហម?

- ចម្លើយៈ បានជាប្រជាជនមិនធ្វើការប៉ះបោរនឹងខ្មែរក្រហម ដោយសារតែៈ ទីមួយ បន្ទាប់ពីខ្មែរក្រហមឡើងកាន់អំណាច ខ្មែរក្រហមបានជម្លៀសប្រជាជនទៅកាន់តំបន់ផ្សេងៗគ្នា ដែលធ្វើឲ្យប្រជាជនមានការពិបាកក្នុងការបង្កើតក្រុម ដើម្បីធ្វើការប្រឆាំងតបតនឹងយោធាខ្មែរក្រហម ។ ទីពីរ នៅតាមទីជនបទ ប្រជាជនខ្មែរត្រូវបានខ្មែរក្រហមឃ្លាំមើលគ្រប់ពេលវេលា ។ ប្រសិនបើ ប្រជាជនណាម្នាក់ត្រូវបានចោទប្រកាន់ថាបាននិយាយអ្វីមិនល្អប៉ះពាល់ដល់បដិវត្តន៍ ប្រជាជនរូបនោះនឹងត្រូវខ្មែរក្រហមចាប់ឃុំឃាំង ធ្វើទារុណកម្ម និងអាចត្រូវបានខ្មែរក្រហមសម្លាប់ ។ កត្តានេះបានបង្កឲ្យមានភាពលំបាកកាន់តែខ្លាំងឡើងសម្រាប់ប្រជាជនកម្ពុជា ដើម្បីរៀបចំក្រុមប៉ះបោរប្រឆាំងនឹងខ្មែរក្រហម ។ ទីបី ដោយសារតែ ប្រជាជនកម្ពុជា ត្រូវបានខ្មែរក្រហម បង្ខំឲ្យធ្វើការធ្ងន់ស្ទើរតែស្លាប់ និងការបង្អត់អាហារ ។ ដូច្នេះ ប្រជាជនកម្ពុជា

ពុំមានកម្លាំង គ្រប់គ្រាន់ក្នុងការប្រឆាំងតបតនឹងខ្មែរក្រហមនោះទេ ។ ទីបួន កម្មាភិបាលខ្មែរក្រហមគ្រប់ភូមិស្រុកមានអាវុធកាន់គ្រប់ដៃ ចំណែកឯប្រជាជនកម្ពុជាពុំមានអាវុធអ្វីអាចធ្វើវាយបកនឹងខ្មែរក្រហមបាននោះទេ ។ នៅក្នុងរបបខ្មែរក្រហម ក៏ធ្លាប់មានព្រឹត្តិការណ៍ប៉ះបោរកើតឡើងដែរ ។ ព្រឹត្តិការណ៍កើតឡើងនៅក្នុងភូមិមួយ នៅពេលដែលមេដឹកនាំខ្មែរអ៊ីស្លាមនៅក្នុងភូមិមួយត្រូវបានខ្មែរក្រហមសម្លាប់ និងការប្រតិបត្តិសាសនា និងប្រពៃណីត្រូវបានលុបបំបាត់ ។ ប៉ុន្តែ ការប៉ះបោររបស់ប្រជាជនខ្មែរអ៊ីស្លាមនៅក្នុងភូមិនោះ ត្រូវបានខ្មែរក្រហមបង្ក្រាបទៅវិញ នៅពេលដែលប្រជាជនខ្មែរអ៊ីស្លាមទាំងនោះពុំមានអាវុធអ្វី ក្រៅពីកាំបិត និងដាវ ។ បន្ទាប់មក ប្រជាជនខ្មែរអ៊ីស្លាមដែលបានចូលរួមប៉ះបោរ ត្រូវបានខ្មែរក្រហមចាប់ឃុំឃាំង ធ្វើទារុណកម្ម និងសម្លាប់ ។

៦. តើតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមផ្តល់យុត្តិធម៌ជូនជនរងគ្រោះខ្មែរក្រហមដែរឬទេ?

- <u>ចម្លើយ</u>: បច្ចុប្បន្ន តុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម បានចេញសាលក្រមទាក់ទងនឹងជនជាប់ចោទ ឈ្មោះ កាំង ហ្គេកអ៊ាវ ហៅ ឌុច ដែលជាមេគុកទួលស្លែង ។ ស្របពេលនឹងគ្នានេះដែរ តុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម កំពុងបន្តដំណើរការកាត់ក្តីទៅលើជនជាប់ចោទពីររូបផ្សេងទៀត ដែលជាអតីតមេដឹកនាំខ្មែរក្រហម រួមមាន នួន ជា និង ខៀវ សំផន ។ បុគ្គលម្នាក់ៗមានការយល់ឃើញខុសគ្នាទៅលើអត្ថន័យនៃពាក្យ "យុត្តិធម៌" ហើយថាតើតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមបានផ្តល់យុត្តិធម៌ជូនជនរងគ្រោះខ្មែរក្រហមដែរឬយ៉ាងណា នោះជាការយល់ឃើញរបស់ជនរងគ្រោះម្នាក់ៗ ។

*សំណួរផ្ញើមកកាន់មជ្ឈមណ្ឌលឯកសារកម្ពុជាដោយៈ*

- *អ៊ុច សុខសិរីមន្នីកា, ខេត្តព្រះវិហារ*
- *ភក្រ្តា, ខេត្តព្រះវិហារ*
- *សុភា, ខេត្តព្រះវិហារ*

នេះគឺជាចុងបញ្ចប់នៃវគ្គទី១០ ក៏ជាវគ្គចុងក្រោយនៃកម្មវិធីវិទ្យុរបស់យើងខ្ញុំ ដែលទាក់ទងនឹងការអត់ឃ្លាន ដែលបានកើតឡើងនៅក្នុងរបបខ្មែរក្រហម ។ មជ្ឈមណ្ឌលឯកសារកម្ពុជា សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះប្រិយមិត្តអ្នកស្តាប់ ដែលបានតាមដានការផ្សាយរបស់យើងខ្ញុំ ។ មជ្ឈមណ្ឌល

ឯកសារកម្ពុជា សូមថ្លែងអំណរគុណ ចំពោះស្ថានីយវិទ្យុផ្សាយសម្លេងសហរដ្ឋអាមេរិក-រាជធានីភ្នំពេញ ដែលបានផ្តល់ស៊ីឌីយោថតសម្លេង ។

កម្មវិធីវិទ្យុនេះឧបត្ថម្ភដោយ នាយកដ្ឋានកម្មវិធីសកលនៃការិយាល័យប្រជាធិបតេយ្យ សិទ្ធិមនុស្ស និង ពលកម្ម របស់ក្រសួងការបរទេសសហរដ្ឋអាមេរិក ។

កម្មវិធីវិទ្យុនេះ ចាក់ផ្សាយរៀងរាល់ថ្ងៃអាទិត្យ តាមរយៈវិទ្យុជាតិកម្ពុជា AM918 KHz រាជធានីភ្នំពេញ វេលាម៉ោង ៩ព្រឹក និង ម៉ោង៧និង៣០នាទីល្ងាច ។ វិទ្យុខេត្តកំពត FM93.25 វេលាម៉ោង៧ព្រឹក និងម៉ោង៧ល្ងាច ។ វិទ្យុខេត្តព្រះវិហារ FM99 វេលាម៉ោង៧និង៣០នាទីព្រឹក និងម៉ោង៤រសៀល ។ វិទ្យុខេត្ត បាត់ដំបង FM103.25 វេលាម៉ោង៨ព្រឹក និង ម៉ោង៤រសៀល ។